**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខ :** ៧៥៤...ស.សណ.ចវ

ថ្ងៃព្រហស្បតិ៍ ៩រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០២០

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

**ជម្រាបជូន**

- **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន**

**កម្មវត្ថុ៖** ករណីរបាយការណ៍ស្តីពីលទ្ធផលនៃការចុះពិនិត្យទីតាំងផលិតទឹកនិងម៉ាស៊ីនខ្មែរអេកូគ្រុង របស់លោកបណ្ឌិត ហេង ប៊ុនអ៊ី។

**យោង៖**
- លិខិតលេខ១៤៣៨ MISTI/២០២០ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០២០ របស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- លិខិតលេខ៤២២ ខន/០២០ សជណ ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០២០ របស់ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៦ ខែសីហា ឆ្នាំ២០២០។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្តីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមជ្រាបថា រាជរដ្ឋាភិបាលសម្រេចដូចខាងក្រោម៖

១-លោកបណ្ឌិត ហេង ប៊ុនអ៊ី ត្រូវធ្វើការចុះបញ្ជីរាល់ផលិតផល និងឧបករណ៍ដែលបានផលិត ដើម្បីទទួលបានភាពស្របច្បាប់តាមការអនុញ្ញាតរបស់ក្រសួង-ស្ថាប័នមានសមត្ថកិច្ច។

២-ផ្អាកការផលិតទឹកអម្រឹត ឬទឹកជា រួមទាំងទឹកសម្លាប់មេរោគជាបណ្តោះអាសន្ន។

៣-ក្រសួងសុខាភិបាល និងក្រសួងពាក់ព័ន្ធត្រូវចេញសេចក្តីណែនាំឱ្យផ្អាកចរាចរជាបណ្តោះអាសន្ននូវការធ្វើអាជីវកម្មទឹកអម្រឹត ឬទឹកជា ដែលកំពុងផលិតដោយម៉ាស៊ីនខ្មែរអេកូគ្រុង របស់លោកបណ្ឌិត ហេង ប៊ុនអ៊ី ហើយការធ្វើចរាចរអាចដំណើរការបាន លុះត្រាតែមានការស្រាវជ្រាវ ពិនិត្យ បញ្ជាក់ និងអនុញ្ញាតពីក្រសួង-ស្ថាប័នជំនាញ។ រាល់ការចែកចាយ ឬចរាចរទឹកដែលផលិតដោយម៉ាស៊ីនខ្មែរអេកូគ្រុង របស់លោកបណ្ឌិត ហេង ប៊ុនអ៊ី បើមានប៉ះពាល់ដល់សុខភាពសាធារណៈត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន។

៤-ក្រសួងព័ត៌មានត្រូវបញ្ឈប់ជាបន្ទាន់នូវរាល់ការផ្សព្វផ្សាយ តាមបណ្ដាញសារព័ត៌មាននានា ក៏ដូចជាបណ្ដាញសង្គមអំពីផលិតផលទឹកអម្រឹត ឬទឹកជា របស់លោកបណ្ឌិត ហេង ប៊ុនអ៊ី ហើយត្រូវរង់ចាំ រហូតទទួលបានគោលការណ៍អនុញ្ញាតតាមច្បាប់របស់ក្រសួង-ស្ថាប័នមានសមត្ថកិច្ច។

៥-ត្រូវមានការជួបពិភាក្សាជាលក្ខណៈបច្ចេកទេសលម្អិត រវាងមន្ត្រីជំនាញរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងលោកបណ្ឌិត ហេង ប៊ុនអ៊ី ដោយមិនមានវត្តមានអ្នកសារព័ត៌មាននានា។

អាស្រ័យដូចបានជម្រាបជូនខាងលើសូមឯកឧត្តមជ្រាបនិងចាត់ចែងអនុវត្ត។

**ជ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការ**

**ឌួយ យុនហ៊ួរ**

**ចម្លងជូន៖**

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- រដ្ឋបាលរាជធានីភ្នំពេញ
- លោកបណ្ឌិត ហេង ប៊ុនអ៊ី
- ឯកសារ កាលប្បវត្តិ